**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# ញត្តិថ្កោលទោស

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ព្រមទាំងបុគ្គលិកទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមធ្វើការថ្កោលទោសយ៉ាងដាច់អហង្ការចំពោះទណ្ឌិត សម រង្ស៊ី ដែលជារឿយៗ បានប្រមាថយ៉ាងធ្ងន់ធ្ងរម្តងហើយម្តងទៀតមកលើអង្គព្រះមហាក្សត្រ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតរបស់ប្រជារាស្ត្រខ្មែរទូទាំងនគរថា "មិនមានមនសិការជាតិ" និង "ក្បត់ជាតិ"។ ទង្វើរបស់ទណ្ឌិត សម រង្ស៊ី ពេលនេះ ជាការបំពានព្រះចេស្តា និងព្រះកិត្តិយសរបស់ព្រះអង្គ ដែលប្រជារាស្ត្រខ្មែរទូទាំងនគរមិនអាចទទួលយក និងអត់ឱនឱ្យបុគ្គលជាទណ្ឌិតរូបនេះបានឡើយ។ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ជាព្រះប្រមុខរដ្ឋ ជារដ្ឋបុរសដែលមានព្រះទ័យស្នេហាជាតិ និងប្រជារាស្ត្រប្រកបដោយទសពិធរាជធម៌យ៉ាងពិតប្រាកដ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតរបស់ប្រជារាស្ត្រខ្មែរ និងជាម្លប់នៃសន្តិភាព សេរីភាព ឯកភាពជាតិ កិត្យានុភាពជាតិ និងវិបុលភាពរបស់ព្រះរាជាណាចក្រកម្ពុជាតាំងពីដើមរៀងមក។

ក្នុងនាមក្រសួងមុខងារសាធារណៈ យើងខ្ញុំទាំងអស់គ្នាមានសេចក្តីខកចិត្តជាពន់ពេក និងសោកស្តាយជាទីបំផុតចំពោះពាក្យសម្តីប្រមាថដ៏អគុណធម៌ និងអកតញ្ញូបំផុតរបស់ទណ្ឌិត សម រង្ស៊ី មកលើ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ក៏ដូចជាមកលើរាជវង្សានុវង្សខ្មែរ ដែលមានគុណបំណាច់មិនអាចកាត់ថ្លៃបានចំពោះមាតុភូមិកម្ពុជា ដែលជាមាតុភូមិកំណើតរបស់ខ្លួនផងដែរនោះ។

ខណៈដែលទណ្ឌិត សម រង្ស៊ី ប្រមាថយ៉ាងធ្ងន់ធ្ងរមកលើអង្គព្រះមហាក្សត្រ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ព្រមទាំងបុគ្គលិកទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមក្រាបបង្គំលើកអញ្ជលីប្រណម្យ បួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក មានទេវតាថែរក្សាព្រះនគរក្រុងកម្ពុជា ព្រមទាំងតេជៈបារមីអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីគ្រប់ព្រះអង្គ សូមប្រទានពរសព្ទសាធុការដល់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** សូមព្រះអង្គមានព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះបញ្ញាញាណភ្លឺថ្លា និងព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជុំសម្រាប់ប្រជារាស្ត្រ កូនចៅ ចៅទួតជាទីស្រឡាញ់របស់ព្រះអង្គ។

ថ្ងៃចន្ទ ១៤រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh